# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការផ្តល់យោបល់លើគោលនយោបាយពាណិជ្ជកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការផ្តល់យោបល់លើគោលនយោបាយពាណិជ្ជកម្ម ដែលសរសេរជាអក្សរកាត់ថា **គ.ផ.គ.ព.** ជាសេនាធិការរបស់រាជរដ្ឋាភិបាលសម្រាប់ផ្តល់យោបល់អំពីការរៀបចំនិងការអនុវត្តគោលនយោបាយពាណិជ្ជកម្មរបស់រាជរដ្ឋាភិបាល ដើម្បីធានាប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការអនុវត្តគោលនយោបាយទាំងនោះ ជាពិសេសការបង្កើនការនាំចេញទៅកាន់ទីផ្សារឬដៃគូពាណិជ្ជកម្មសក្តានុពលតាមរយៈការពង្រឹងសមត្ថភាពផលិតកម្មនៃឧស្សាហកម្មក្នុងស្រុក ឱ្យស្របតាមលក្ខខណ្ឌទីផ្សារនីមួយៗ។

## ជំពូកទី២

## តួនាទីនិងភារកិច្ចរបស់ គ.ផ.គ.ព.

**មាត្រា២ .-**

**គ.ផ.គ.ព.** មានតួនាទីជាសេនាធិការរបស់រាជរដ្ឋាភិបាលនិងមានភារកិច្ចដូចតទៅ៖



https://www.moj.gov.kh/kh/law-regular

- ផ្តល់យោបល់លើភាពខ្លាំងនិងភាពខ្សោយនៃការរៀបចំនិងការអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងពាណិជ្ជកម្មនិងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីសម្រាប់ព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅជានាប្រសិទ្ធភាពនៃការអនុវត្ត និងស្របតាមលក្ខខណ្ឌនិងអត្ថប្រយោជន៍ជាក់ស្តែងរបស់កម្ពុជា
- លើកយោបល់និងរៀបចំជំនួយស្មារតីលើផ្នែកគោលនយោយពាណិជ្ជកម្ម សក្តានុពលពាណិជ្ជកម្មទាំងទំនិញនិងសេវា ក៏ដូចជាចំណុចសំខាន់ៗពាក់ព័ន្ធវិស័យពាណិជ្ជកម្មរបស់ប្រទេសឬតំបន់ដែលប្រមុខរាជរដ្ឋាភិបាលត្រូវធ្វើដំណើរទស្សនកិច្ច
- ធ្វើការសិក្សានិងលើកយោបល់ជូនរាជរដ្ឋាភិបាលអំពីទីផ្សារនាំចេញ ឬដៃគូពាណិជ្ជកម្មសក្តានុពលដែលព្រះរាជាណាចក្រកម្ពុជាចរចាបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ក្នុងរយៈពេលខ្លីនិងមធ្យមខាងមុខទាំងក្នុងកម្រិតទ្វេភាគីនិងពហុភាគី ព្រមទាំងកំណត់មុខទំនិញនិងសេវាអាទិភាព ទាំងទំនិញនិងសេវាដែលព្រះរាជាណាចក្រកម្ពុជាកំពុងផលិត និងមុខទំនិញដែលត្រូវផលិតសម្រាប់ការនាំចេញស្របតាមទីផ្សារនីមួយៗ
- តាមដានជាប្រចាំនូវរាល់ការប្រែប្រួលនៃស្ថានភាពភូមិសាស្ត្រនយោបាយ គោលនយោបាយសេដ្ឋកិច្ចនិងពាណិជ្ជកម្មក្នុងតំបន់និងសកលលោក ជាពិសេសក្នុងបរិការណ៍នៃការផ្លាស់ប្តូររដ្ឋាភិបាលនៃមហាអំណាចសេដ្ឋកិច្ច និងការប្រែប្រួលដ៏ឆាប់រហ័សនៃបរិយាកាសពាណិជ្ជកម្មអន្តរជាតិមកលើសេដ្ឋកិច្ចកម្ពុជា និងលើកជាយោបល់និងវិធានការគោលនយោបាយជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីត្រៀមលក្ខណៈសម្បត្តិចាត់វិធានការទប់ទល់ឬបញ្ចៀសបញ្ហា
- ធ្វើការពិនិត្យនិងវាយតម្លៃលើសមត្ថភាពឧស្សាហកម្មក្នុងស្រុក ព្រមទាំងតម្រង់ទិសលើការពង្រឹងសមត្ថភាពផលិតទំនិញអាទិភាព សម្រាប់ការនាំចេញ ស្របតាមទីផ្សារនីមួយៗ
- ផ្តល់ព័ត៌មាននិងអនុសាសន៍ តាមរយៈការវិភាគលើផលប៉ះពាល់ពីការប្រែប្រួលតាមស្ថានភាពជាក់ស្តែងនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលចូលជាធរមានរួច
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

## ជំពូកទី៣
## សមាសភាពរបស់ គ.ផ.គ.ព.

**មាត្រា៣ .-**

**គ.ផ.គ.ព.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - ទេសរដ្ឋមន្ត្រី ១រូប | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | អនុប្រធានប្រចាំការ |
| - រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល ១រូប | សមាជិក |



https://www.moj.gov.kh/kh/law-regular

- រដ្ឋលេខាធិការក្រសួងបរិស្ថាន ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ១រូប សមាជិក
- អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
- អគ្គលេខាធិការឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ សមាជិក
- អគ្គទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ១រូប សមាជិក
- តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ១រូប សមាជិក
- តំណាងអគ្គនាយកដ្ឋានពន្ធដារ ១រូប សមាជិក
- តំណាងរាជបណ្ឌិត្យសភាកម្ពុជា ១រូប សមាជិក
- តំណាងសភាពាណិជ្ជកម្មកម្ពុជា ១រូប សមាជិក
- តំណាងសមាគមឧកញ៉ាកម្ពុជា ១រូប សមាជិក
- តំណាងសមាគមរោងចក្រកាត់ដេរនិងស្បែកជើងនៅកម្ពុជា ១រូប សមាជិក
- តំណាងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ១រូប សមាជិក
- តំណាងវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ១រូប សមាជិក
- តំណាងវិទ្យាស្ថានចក្ខុវិស័យអាស៊ី ១រូប សមាជិក
- ប្រធានលេខាធិការដ្ឋាននៃ **គ.ផ.គ.ព.** សមាជិកអចិន្ត្រៃយ៍។

សមាសភាពជាក់ស្តែងរបស់ **គ.ផ.គ.ព.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**គ.ផ.គ.ព.** អាចមានសមាសភាពបន្ថែមជាអនុប្រធាននិងសមាជិកតាមការចាំបាច់។ សមាសភាពបន្ថែមនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ផ.គ.ព.

**មាត្រា៤ .-**

ប្រធាន **គ.ផ.គ.ព.** ដឹកនាំកិច្ចការទូទៅរបស់ **គ.ផ.គ.ព.** ។ នៅពេលដែលប្រធាន **គ.ផ.គ.ព.** អវត្តមានឬមានធុរៈចាំបាច់ ប្រធាន **គ.ផ.គ.ព.** អាចប្រគល់សិទ្ធិជូនអនុប្រធានប្រចាំការឱ្យទទួលដឹកនាំការងារប្រចាំថ្ងៃ របស់ **គ.ផ.គ.ព.** ក្នុងឋានៈជាប្រធានស្តីទី រហូតដល់មានវត្តមានប្រធាន **គ.ផ.គ.ព.**។

អនុប្រធាននិងអនុប្រធានប្រចាំការ **គ.ផ.គ.ព.** អនុវត្តការងារតាមការកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ផ.គ.ព.**។

**មាត្រា៥ .-**

**គ.ផ.គ.ព.** ត្រូវប្រជុំរៀងរាល់មួយខែម្តង តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ ប្រធាន **គ.ផ.គ.ព.** អាចកោះប្រជុំជាវិសាមញ្ញបាន។

អនុប្រធាន អនុប្រធានប្រចាំការ និងសមាជិកនៃ **គ.ផ.គ.ព.** ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.ផ.គ.ព.**។

របៀបរបបការងារនិងកិច្ចដំណើរការប្រជុំរបស់ **គ.ផ.គ.ព.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **គ.ផ.គ.ព.**។



https://www.moj.gov.kh/kh/law-regular

**មាត្រា៦ .-**

**គ.ផ.គ.ព.** អាចអញ្ជើញថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ឬឥស្សរជនដែលមានបទពិសោធ សមត្ថភាព និងជំនាញវិជ្ជាជីវៈ ចូលរួមពិគ្រោះយោបល់ និងបំភ្លឺរាល់បញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងក្របខ័ណ្ឌការងាររបស់ខ្លួន និងការងារចាំបាច់នានាដែលត្រូវទទួលអនុវត្ត។

**មាត្រា៧ .-**

**គ.ផ.គ.ព.** អាចមានទីប្រឹក្សានិងជំនួយការមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ទីប្រឹក្សានិងជំនួយការ **គ.ផ.គ.ព.** ត្រូវតែងតាំងដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ។

**មាត្រា៨ .-**

**គ.ផ.គ.ព.** មានក្រុមការងារយុទ្ធសាស្ត្រ ដើម្បីជួយតម្រង់ទិសដៅការងារលើខ្លឹមសារជាយុទ្ធសាស្ត្រក្នុងកិច្ចការគោលនយោបាយពាក់ព័ន្ធនឹងពាណិជ្ជកម្មនិងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរបស់កម្ពុជា ដើម្បីផ្សារភ្ជាប់និងឆ្លើយតបនឹងកិច្ចការប្រតិបត្តិរបស់រាជរដ្ឋាភិបាល។

ក្រុមការងារយុទ្ធសាស្ត្រនៃ **គ.ផ.គ.ព.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - ទេសរដ្ឋមន្ត្រី ១រូប | ប្រធាន |
| - តំណាងក្រសួងពាណិជ្ជកម្ម ១រូប | អនុប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | អនុប្រធាន |
| - តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១រូប | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |
| - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប | សមាជិក |
| - តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១រូប | សមាជិក |
| - តំណាងក្រសួងបរិស្ថាន ១រូប | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ១រូប | សមាជិក |
| - តំណាងវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ១រូប | សមាជិក |
| - តំណាងខុទ្ទកាល័យទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធាន **គ.ផ.គ.ព.** ១រូប | សមាជិក |
| - ប្រធានលេខាធិការដ្ឋាន **គ.ផ.គ.ព.** | សមាជិក។ |

សមាសភាពជាក់ស្តែងរបស់ក្រុមការងារយុទ្ធសាស្ត្ររបស់ **គ.ផ.គ.ព.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលឬដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីតាមការប្រគល់សិទ្ធិពីនាយករដ្ឋមន្ត្រី។

ក្រុមការងារយុទ្ធសាស្ត្ររបស់ **គ.ផ.គ.ព.** អាចមានសមាសភាពបន្ថែមជាអនុប្រធាននិងសមាជិកតាមការចាំបាច់។ សមាសភាពត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលឬដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីតាមការប្រគល់សិទ្ធិពីនាយករដ្ឋមន្ត្រី។



https://www.moj.gov.kh/kh/law-regular

**មាត្រា៩ .-**

**គ.ផ.គ.ព.** មានលេខាធិការដ្ឋានមួយជាសេនាធិការសម្រាប់ដំណើរការការងារប្រចាំថ្ងៃ ដែលមានទីតាំងនៅទីស្ដីការគណៈរដ្ឋមន្ត្រី។

លេខាធិការដ្ឋាននៃ **គ.ផ.គ.ព.** ដឹកនាំដោយប្រធាន១(មួយ)រូប និងមានអនុប្រធាននិងសមាជិកមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ប្រធាន អនុប្រធាន និងសមាជិកលេខាធិការដ្ឋាននៃ **គ.ផ.គ.ព.** ត្រូវតែងតាំងដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ។ ក្នុងករណីចាំបាច់ លេខាធិការដ្ឋាននៃ **គ.ផ.គ.ព.** អាចស្នើសុំជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាឱ្យជួយការងារ។

**មាត្រា១០ .-**

លេខាធិការដ្ឋាននៃ **គ.ផ.គ.ព.** មានភារកិច្ចដូចតទៅ៖

- សម្របសម្រួលនិងទទួលបន្ទុកការងារប្រចាំថ្ងៃរបស់ **គ.ផ.គ.ព.**
- តាមដាននិងធ្វើរបាយការណ៍ជាប្រចាំនូវរាល់ការប្រែប្រួលនៃស្ថានភាពភូមិសាស្ត្រនយោបាយ គោលនយោបាយសេដ្ឋកិច្ច និងពាណិជ្ជកម្មក្នុងតំបន់ និងសកលលោកជូន **គ.ផ.គ.ព.**
- ទទួលបន្ទុករៀបចំ គ្រប់គ្រង និងចាត់ចែងថវិការបស់ **គ.ផ.គ.ព.**
- ទទួលបន្ទុករៀបចំ គ្រប់គ្រង និងចាត់ចែងសម្ភារៈ បរិក្ខាររបស់ **គ.ផ.គ.ព.**
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំស្ដីពីសកម្មភាពរបស់ **គ.ផ.គ.ព.**
- គ្រប់គ្រងឯកសារចេញ ចូល
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធាន **គ.ផ.គ.ព.** ។

**មាត្រា១១ .-**

**គ.ផ.គ.ព.** និងលេខាធិការដ្ឋាននៃ **គ.ផ.គ.ព.** មានសិទ្ធិប្រើត្រារបស់ទីស្ដីការគណៈរដ្ឋមន្ត្រីដើម្បីដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួន។

## ជំពូកទី៥
## ប្រភពធនធានរបស់ គ.ផ.គ.ព.

**មាត្រា១២ .-**

**គ.ផ.គ.ព.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ថវិកា នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី។

**គ.ផ.គ.ព.** មានសិទ្ធិទទួល ប្រើប្រាស់ និងចាត់ចែងតាមនីតិវិធីដូចមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននូវប្រភពធនធានដែលបានមកពីដៃគូអភិវឌ្ឍ និងប្រភពស្របច្បាប់ផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។



https://www.moj.gov.kh/kh/law-regular

**មាត្រា១៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាទៅ។

ថ្ងៃចន្ទ ១០កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



https://www.moj.gov.kh/kh/law-regular